ASRIC
Applied Social Research Institute of Cambodia

CJA THE CENTER FOR JUSTICE & ACCOUNTABILITY
Bringing Human Rights Abusers To Justice.

# សំរាប់ផលប្រយោជន៍របស់អ្នក
# លិខិតនេះគឺជាសេចក្តីបន្ថែមថ្មីមួយដែលត្រូវបានបកប្រែជាខេមរភាសារបស់តុលាការដែលបានផ្ញើរនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១

ជូនចំពោះដើមបណ្តឹងរដ្ឋប្បវេណីជាទីគោរព:

ខ្ញុំសសេរលិខិតនេះ ដើម្បីចែករំលែកនូវពត៏មានដ៏រីករាយមួយដល់អ្នកទាំងអស់គ្នាថាដោយការកាត់ក្តីនៅលើកទីពីរមុននឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) នឹងចាប់ផ្តើមនថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ នៅក្នុងរាជធានីភ្នំពេញ។ ប្រហែលជាអ្នកទាំងអស់គ្នានៅចងចាំថា វិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជា (ASRIC) បានដាក់ពាក្យសុំចូលរួមក្នុងការកាត់ក្តីនេះតំណាងអោយអ្នកទាំងអស់គ្នា ហើយអ្នកទាំងអស់គ្នាក៏ត្រូវបានអនុញ្ញាតជាផ្លូវការក្នុងនាមជាភាគី ប្រឆាំងនឹងនួន ជា, អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន ក្នុងសំណុំរឿង០០២។ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រហែលជិត៣៩០០នាក់ចូលរួមក្នុងសំណុំរឿង០០២ ហើយដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនមកពីបណ្តាខេត្តនានានៃ ប្រទេសកម្ពុជា ព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណី ចំនួន៩៩នាក់មកពីសហរដ្ឋអាមេរិក។ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ កសិណសាក្សីរបស់អ្នកនឹងក្លាយទៅជាភស្តុតាងដែលអាចជួយក្នុងការកាត់ក្តី ចុងចោទក្នុងតុលាការវិនិច្ឆ័យទោសនាពេលបច្ចុប្បន្ននេះ។

កាលពីម្សិលមិញតុលាការបានប្រកាសថា ចុងចោទអៀងធីរិទ្ធនឹងមិនចូលរួមក្នុងការកាត់ក្តីទេ។ អៀងធីរិទ្ធគឺជា ប្រពន្ធរបស់ អៀង សារី ហើយក៏ជាអតីតរដ្ឋមន្ត្រីកិច្ចការសង្គមនៅសម័យខ្មែរក្រហម។ កាលពីមុនអ្នកជំនាញវិជ្ជាពេទ្យបានអះអាងដល់តុលាការថាអៀងធីរិទ្ធ បានបាត់បង់ការចងចាំ ប្រហែលជាជំងឺភ្លេចភ្លាំងដោយសារតែវ័យចំណាស់របស់គាត់ ព្រមទាំងនិយាយទៀតថា គាត់មិនអាចចងចាំនូវអ្វីដែលបានកើតឡើងក្នុងសម័យខ្មែរក្រហមទេ ហើយក៏មិនអាចយល់នូវការកាត់ក្តីមកលើរូបគាត់បានដែរ។ នៅក្រោមប្រព័ន្ធច្បាប់ភាគច្រើន បុគ្គលម្នាក់ដែលមានបញ្ហាខាងខួរក្បាល/សតិអារម្មណ៏ មិនអាចបង្ខំអោយចូលរួមការកាត់ក្តីបានទេ ប្រសិនបើបុគ្គលនោះមិនយល់ពីភស្តុតាងរឺការកាត់ក្តីផ្ទាល់។ ដោយសារតែពេលនេះ តុលាការបានរកឃើញថា គាត់ពិតជាមានបញ្ហាខាងខួរក្បាល/សតិអារម្មណ៏មែនដូចនេះគាត់នឹងមិនចូលរួមក្នុងការកាត់ក្តីជាចុងចោទ ក្នុងសំណុំរឿង០០២បានទេ ហើយការកាត់ទោសនឹងបន្តការកាត់ក្តីចុងចោទបីនាក់ទៀត ដែលរួមមាននួន ជា, អៀង សារី, និង ខៀវសំផន។

មជ្ឈមណ្ឌលយុត្តិធម៌និងគណនីភាព (CJA) នឹងតំណាងអោយអ្នកទាំងអស់គ្នាក្នុងអំឡុងពេលការកាត់ទោស ហើយ នឹងសហការធ្វើការយ៉ាងជិតស្និទជាមួយនឹងវិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជា(ASRIC) ដើម្បីជួយផ្តល់ដំណឹងថ្មីៗទៅ លើបញ្ហាសំខាន់ៗដល់អ្នក។ យើងនឹងធ្វើការយ៉ាងជិតស្និទជាមួយនឹងក្រុមដើមបណ្តឹងរដ្ឋប្បវេណី អង្គការក្រៅរដ្ឋាភិបាល និង អង្គភាពគំពារជនរងគ្រោះ

ASRIC,c/o A/P/A Institute NYU, 41-51 E. 11th Street, New York, NY 10003, tel (212) 300- 5775www.apa.nyu.edu/ASRIC;
CJA, 870 Market Street, Suite 680 San Francisco, CA 94102, tel (415) 544 0444, fax (415) 544 0456 www.cja.org

នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីបង្កើតនូវសំណងសំរាប់ជនរងគ្រោះនាសម័យខ្មែរក្រហម។ សំណងទាំងនេះគឺជាសំណងនិមិត្តសញ្ញាដែលទទួលស្គាល់ការពិតនូវការធ្វើទុក្ខទោសដល់ជនរងគ្រោះក្នុងសម័យខ្មែរក្រហម ហើយនឹងត្រូវប្រគល់អោយនូវពេលចុងបញ្ចប់នៃការកាត់ក្តី។ លោកបណ្ឌិត លក្ខិណា នូ មកពីវិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជា(ASRIC) ហើយនិងមេធាវីរបស់អ្នកទាំងអស់គ្នានៅឯមជ្ឈមណ្ឌលយុត្តិធម៌និងគណនីភាព (CJA) ដែលមានឈ្មោះថា Nushin Sarkarati នឹងមានវត្តមាននៅទីក្រុងភ្នំពេញចាប់ពី ថ្ងៃទី២១ ខែវិច្ឆិកា រហូតដល់ពាក់កណ្តាលខែធ្នូ ឆ្នាំ២០១១ ដើម្បីតំណាងអោយផលប្រយោជន៍នៃជនដែលរស់រានមានជីវិតពីរបបខ្មែរក្រហមហើយកំពុងតែរស់នៅក្នុងសហរដ្ឋអាមេរិកមុននិងមានការកាត់ក្តី។ ដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសហរដ្ឋអាមេរិកចំនួន៣នាក់នឹងធ្វើការសង្កេតសប្តាហ៍ទីមួយនៃការ កាត់ក្តីនៅរាជធានីភ្នំពេញ។

ដូចដែលយើងបានពន្យល់ពីមុនមក មជ្ឈមណ្ឌលយុត្តិធម៌និងគណនីភាព (CJA) នឹងផ្តល់អោយអ្នកនូវការតំណាងស្របច្បាប់នៅក្នុងបណ្តឹងទាំងនេះដោយគ្មានការយកកំរៃអ្វីឡើយ។ សូមកុំមានអារម្មណ៍ស្ទាក់ស្ទើរក្នុងការទាក់ទងមកមេធាវី Nushin Sarkarati ប្រចាំមជ្ឈមណ្ឌលយុត្តិធម៌ និងគណនីភាព (CJA) ប្រសិនបើអ្នកមានជាសំនួរ រឺកង្វល់អ្វីទាក់ទងនឹងបណ្តឹង រឺក៏ តួនាទីរបស់អ្នកក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីសូមទំនាក់ទំនង តាមរយៈទូរស័ព្ទលេខ (៤១៥) ៥៤៤-០៤៤៤ បន្តទៅលេខ ៣១៨ រឺតាមរយៈអ៊ីមែល nsarkarati@cja.org។ អ្នកក៏អាចទាក់ទងបានដែរមកកាន់លោកបណ្ឌិត លក្ខិណា នូ ប្រចាំវិទ្យាស្ថានស្រាវជ្រាវអនុវត្តន៍សង្គមកម្ពុជា(ASRIC)តាមរយៈទូរស័ព្ទលេខ (២១២) ៣០០-៥៧៧៥ រឺតាមរយៈអ៊ីមែល apa.asric-khmer.justice@nyu.edu។

ដោយសេចក្តីគោរពយ៉ាងស្មោះត្រង់ពីយើងខ្ញុំ